ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបាត់ដំបង
សំណុំរឿងព្រហ្មទណ្ឌ
លេខ៖៣៤៦/២៤-០៤-១៩
សំណុំរឿងជំនុំជម្រះ
លេខ៖៨៨២/០៩-០៩-២០
សាលក្រមព្រហ្មទណ្ឌ
លេខ៖១១៧២"ក"/២១-០៩-២០

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តបាត់ដំបង និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ ត្រូវនឹងថ្ងៃច័ន្ទ ៤កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ពស២៥៦៤ ដែលមានសមាសភាពដូចតទៅ ៖

## ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តបាត់ដំបង

## ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តបាត់ដំបង

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តបាត់ដំបង

## តំណាងអយ្យការ

ឯកឧត្តម [redacted] ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តបាត់ដំបង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៤៦ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ ៖

-ឈ្មោះ [redacted] ឧត្តម ហៅ ហ៊ុង ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូមិស្ពានកណ្តោល ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង សាសនាព្រះពុទ្ធ មុខរបរនៅផ្ទះ មានទីលំនៅ [redacted] ស្រុកបវេល ខេត្តបាត់ដំបង ប្រពន្ធឈ្មោះ [redacted] (លែងលះ) ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) កម្រិតវប្បធម៌ថ្នាក់ទី១២ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (គេចខ្លួន)

-ដីកាបង្គាប់ឱ្យនាំខ្លួនលេខ ៦៨៥ ត-ព្រ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ ។

-ជាប់ចោទពីបទ៖ ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ - តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ ។

-លោក [redacted] អត្តលេខ ១១៨១ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឧត្តម ហៅ ហុង ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីហា ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ។

-ជនរងគ្រោះឈ្មោះ [redacted] គីមហុង ភេទស្រី អាយុ១៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២២៣៤ ដស-សព ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញដីកាដំណោះស្រាយលេខ ៧៨៨ ដ-ផ-រ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ៧៣៧៣ ក-ព្រ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០២០ របស់ប្រធានសាលាដំបូងខេត្តបាត់ដំបង ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ៖

កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង៤និង៣០នាទី ទាបភ្លឺ នៅចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ជនជាប់ចោទឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ ២១ឆ្នាំ បានធ្វើសកម្មភាពប៉ុនប៉ងរំលោភប្អូនថ្លៃស្រីរបស់ខ្លួនឈ្មោះ [redacted] គីមហុង អាយុ១៤ឆ្នាំ ដែលនាងកំពុងគេងនៅក្នុងបន្ទប់តែម្នាក់ឯង ព្រោះថាពេលនោះឪពុកម្តាយ និងជីដូន បានក្រោកទៅហែទានវស្សាអស់ ។ ដោយឃើញដូច្នេះ ឈ្មោះ [redacted] ឧត្តម បានចូលទៅក្នុងបន្ទប់ប្អូនថ្លៃឈ្មោះ [redacted] គីមហុង ពេលនាងកំពុងគេងលក់ ហើយបានធ្វើសកម្មភាពសម្រាតខោអាវរបស់ប្អូនថ្លៃដល់ត្រឹមជង្គង់ ប៉ុន្តែត្រូវឈ្មោះ [redacted] គីមហុង ទាក់ចំប្រដាប់ភេទជនជាប់ចោទ និងរើបំរាស់ តែត្រូវឈ្មោះ [redacted] ឧត្តម ចាប់ទាញសក់ឱ្យគេងលើពូកវិញ ហើយបានយកខ្នើយមកខ្ទប់មាត់ ពេលនោះឈ្មោះ [redacted] គីមហុង ខំរើបំរាស់ម្តងទៀត ដោយយកជើងធាក់ចំឈ្មោះ [redacted] ឧត្តម បណ្តាលឱ្យចុកហួល ហើយឈ្មោះ [redacted] ឧត្តម បានដើរចេញ ដោយបានគំរាមថា បើប្រាប់ប៉ាម៉ាក់ឱ្យដឹង នឹងមានរឿងហើយ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ឧត្តម អវត្តមាន ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីហា វត្តមាន ជនរងគ្រោះឈ្មោះ [redacted] គីមហុង វត្តមាន សាក្សីឈ្មោះ [redacted] ស្រីពៅ អវត្តមាន សាក្សីឈ្មោះ [redacted] គីមហ៊ួច អវត្តមាន ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] សីហា បានឆ្លើយថា ៖ ខ្លួនពុំបានឃើញរឿងហេតុដែលបានកើតឡើងទេ តែខ្លួនដឹងរឿង ដោយសារកូនបានប្រាប់ ។ ខ្លួននៅតែប្តឹងដដែល ។ ខ្លួនទាមទារសំណងជំងឺចិត្តចំនួន៥០,០០០ដុល្លារ ។

-ជនរងគ្រោះឈ្មោះ[redacted] គីមហុង បានឆ្លើយថា ៖ ខ្លួនស្គាល់ឈ្មោះ[redacted] ឧត្តម ដោយគាត់ត្រូវជាបងថ្លៃរបស់ខ្លួន គាត់បានមកចាប់រំលោភខ្លួន នៅផ្ទះ នៅផ្សារបវេល ។ ឈ្មោះ[redacted] ឧត្តម បានយកប្រដាប់ភេទរបស់គាត់ ដាក់ចូលក្នុងប្រដាប់ភេទរបស់ខ្លួន ។ បន្ទាប់ពីកើតហេតុហើយ ខ្លួនមិនបានទៅពេទ្យពិនិត្យប្រដាប់ភេទ ទេ ។ ឈ្មោះ[redacted] ឧត្តម បានចាប់រំលោភខ្លួនបានសម្រេច មែន ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន ៖ ឆ្លងតាមការដេញដោលនាពេលសវនាការ និងក្រោយពីបានពិនិត្យសំណុំរឿង រួចមក ឃើញថា ពិតជាមានអង្គហេតុដូចការចោទប្រកាន់ មែន ។ ចំណែកជនជាប់ចោទបានគេចខ្លួនពីមូលដ្ឋាន ដូច្នេះគ្មានភស្តុតាងដោះបន្ទុកឡើយ ។ ដូច្នេះតំណាងអយ្យការស្នើសុំតម្កល់បទចោទប្រកាន់ ទុកនៅជាត្រឹមត្រូវដដែល និងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទ តាមផ្លូវច្បាប់ ។

-លោកមេធាវី [redacted] វុទ្ធី បានធ្វើសេចក្តីសន្និដ្ឋាន ៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការ រួចមក ឃើញថា កូនក្តីរបស់ខ្លួនពុំបានចូលមកបំភ្លឺនៅគ្រប់នីតិវិធី របស់តុលាការ ឡើយ ហើយមានតែចម្លើយដាក់បន្ទុកពីដើមបណ្តឹងនិងជនរងគ្រោះ តែប៉ុណ្ណោះ ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិចារណា តាមផ្លូវច្បាប់ ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ០៨និង៣០នាទី ទៀបភ្លឺ **នៅចំណុចភូមិ**បវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង មានករណី " **ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** " មួយបានកើតឡើងដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] **ឧត្តម** ហៅ **ហុង** ភេទប្រុស អាយុ២១ឆ្នាំ បានធ្វើសកម្មភាពចាប់បង្ខំប៉ុនប៉ងរំលោភប្អូនថ្លៃស្រីឈ្មោះ[redacted] **គីមហុង** អាយុ១៨ឆ្នាំ ពេលដែលជនរងគ្រោះកំពុងគេងក្នុងបន្ទប់ម្នាក់ឯង ពិតប្រាកដមែន ។

សន្ទុះក្រោយមកឈ្មោះ [redacted] ឧត្តម បានដើរចូលទៅក្នុងបន្ទប់ឈ្មោះ [redacted] គីមហុង ដែលមានបន្ទប់ក្បែរគ្នា ហើយខ្លួនឮឈ្មោះ [redacted] គីមហុង ស្រែកបន្តិចក៏បាត់ទៅវិញ ។

-តាមលិខិត(ឯកសារលេខ១០) ដែលមានស្នាមម្រាមដៃឈ្មោះ [redacted] ឧត្តម ឈ្មោះ [redacted] គីមមុយ និងឈ្មោះ [redacted] ប៊ុនថន បានន័យថា ៖ ឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ២១ឆ្នាំ មានកំហុសយ៉ាងធំធេង ពីបទចាប់រំលោភប្អូនថ្លៃម្នាក់ មានឈ្មោះ **គីមហុង** ។

-ចម្លើយរបស់ជនរងគ្រោះ ចម្លើយរបស់សាក្សី និងលិខិត(ឯកសារលេខ១០) មានភាពស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងលទ្ធផលនៃការស៊ើបសួរ ដែលអាចកំណត់បានថា ជនជាប់ចោទឈ្មោះ [redacted] ឧត្តម ហៅ ហុង ពិតជាបានប្រព្រឹត្តអំពើ " **ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** " តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ ពិតប្រាកដមែន ។

-ចម្លើយដោះសាររបស់ជនជាប់ចោទនៅសមត្ថកិច្ច ថាខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះ គឺគ្រាន់តែជាលេសដោះសារ ដើម្បីឱ្យខ្លួនរួចផុតការទទួលខុសត្រូវព្រហ្មទណ្ឌ តែប៉ុណ្ណោះ ។

-ជនជាប់ចោទឈ្មោះ [redacted] ឧត្តម ហៅ ហុង បានគេចខ្លួនបាត់ពីមូលដ្ឋាន ដូច្នេះគ្មានភស្តុតាងណា អាចដោះបន្ទុកបានថា ជនជាប់ចោទរូបនេះ មិនបានប្រព្រឹត្តអំពើ " **ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** " តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ ឡើយ ។

-ជនជាប់ចោទខាងលើ ជានីតិជន និងជាសមត្ថជនដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងច្បាប់របស់រដ្ឋ ។

-មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើ ៖ ឈ្មោះ [redacted] ឧត្តម ហៅ ហុង ភេទប្រុស អាយុ២១ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ពីបទ " **ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** " តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីហា បានសំណូមពរសុំទាមទារសំណងជំងឺចិត្តចំនួន ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក គប្បីតុលាការលើកយកមកពិចារណា លើតាមព្យសនៈកម្ម ជាក់ស្តែង ។

-ជនជាប់ចោទឈ្មោះ [redacted] ឧត្តម ហៅ ហុង បានគេចខ្លួនបាត់ពីមូលដ្ឋាន ហើយតុលាការនឹងធ្វើការប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារលើជនជាប់ចោទ លើសពី១ឆ្នាំ ដោយគ្មានការព្យួរទោស

នោះទេ ដូច្នេះផ្អែកតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីតុលាការ ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទ ដែលអវត្តមាន ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសដាក់ពន្ធនាគារលើ ៖ ឈ្មោះ [redacted] ឧត្តម ហៅ ហុង ភេទប្រុស អាយុ២១ឆ្នាំ (មានសាវតារជាតិដូចខាងលើ) កំណត់រយៈពេល ០៨ឆ្នាំ(ប្រាំបីឆ្នាំ) គិតចាប់ពីថ្ងៃចាប់ខ្លួនបានយកមកអនុវត្តទោសក្នុងពន្ធនាគារ ពីបទ - ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ - តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ ។

២-បង្គាប់មកជនជាប់ចោទឈ្មោះ [redacted] ឧត្តម ឱ្យសងសំណងជំងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណី ចំនួន៦០,០០០,០០០រៀល(ហុកសិបលានរៀល) ការទាមទារលើសពីនេះ ត្រូវបដិសេធចោល ។

៣-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ៖ ឈ្មោះ [redacted] ឧត្តម តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ ត្រូវនឹងថ្ងៃចន្ទ ៤កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ពស២៥៦៤ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ឧត្តម ហៅ ហុង ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីហា ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមការកំណត់នៃច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |